E218.1

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 03 / 08 / 2012
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

---

**ឧបសម្ព័ន្ធ-អង្គជំនុំជម្រះសាលាដំបូង** **សាធារណៈ / Public**

ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២

**ជូនចំពោះ:** **ភាគីនៃសំណុំរឿង០០២**

**ពី:** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ:** **សំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំពង្រីកវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ (ឯកសារ E163)**

១. ក្នុងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់ខ្លួន ដោយអនុលោមតាមវិធាន ៨៩ *ស្ទួន២* នៃវិធានផ្ទៃក្នុង (ឯកសារ E124) អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់ថា "នៅក្នុងដំណាក់កាលណាមួយក៏បាន អង្គជំនុំជម្រះសាលាដំបូងអាចសម្រេចដាក់បញ្ចូលបន្ថែមនូវផ្នែកផ្សេងទៀត នៃដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០២ ប្រសិនបើជនជាប់ចោទទទួលបាននូវឱកាសក្នុងការរៀបចំការការពារបានប្រកបដោយប្រសិទ្ធភាព ហើយភាគីនានាត្រូវបានជូនដំណឹងក្នុងរយៈពេលសមស្រប"[1]។ ចាប់តាំងពីពេលនោះមក អង្គជំនុំជម្រះបានគូសបញ្ជាក់ម្តងហើយ ម្តងទៀតថាក្នុងការអនុវត្តឆន្ទានុសិទ្ធិលើការរៀបចំសវនាការរបស់ខ្លួន ការពង្រីកវិសាលភាពនៃការជំនុំជម្រះអាចត្រូវបានពិចារណាទៅតាម

---

[1] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ ស្ទួនពីរនៃវិធានផ្ទៃក្នុង, ឯកសារ E124, ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១, កថាខណ្ឌ ៦-៧ ("ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី")។

ភាពជាក់ស្តែង ដែលនៅពេលនោះ សំណូមពររបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងប្រធានបទបន្ថែម ដែលអាចដាក់បញ្ចូលនៅក្នុងសវនាការដំណាក់កាលដំបូង នឹងត្រូវលើកយកមកពិចារណា[2]។

២. អង្គជំនុំជម្រះបានពិចារណាអំពីសំណូមពររបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងការពង្រីកវិសាលភាពនៃការជំនុំជម្រះដំណាក់កាលដំបូងក្នុងសំណុំរឿង ០០២/០១ និងពិសេស សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំដាក់ទីតាំងឧក្រិដ្ឋកម្មបន្ថែមចំនួន ០៣ កន្លែង និងការចោទប្រកាន់លើអង្គហេតុពីក្នុងដីកាដំណោះស្រាយ៖

i) ការសម្លាប់នៅស្រុក ១២

ii) ការសម្លាប់អតីតទាហាន លន់ នល់ និងអ្នករដ្ឋការនៅទួលពោធិ៍ជ្រៃ និង

iii) មន្ទីរសន្តិសុខ ស-២១ និងទីកន្លែងសម្លាប់មនុស្សពាក់ព័ន្ធនៅជើងឯក[3]

៣. អង្គជំនុំជម្រះសាលាដំបូងឯកភាពជាមួយសហព្រះរាជអាជ្ញាដែលថា ការបន្ថែមទីតាំងបន្ថែមដែលបានស្នើឡើងទាំងនេះ អាចជាការភ្ជាប់ទំនាក់ទំនងជាមួយលំដាប់លំដោយកាលប្បវត្តិត្រឹមត្រូវ នៃហេតុការណ៍ដែលនឹងត្រូវស្តាប់ក្នុងសវនាការនៃសំណុំរឿង ០០២/០១។ ការជូនដំណឹងគ្រប់គ្រាន់ទៅភាគីអាចត្រូវ

---

[2] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំការពិចារណាឡើងវិញ អំពីដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើពាក់ព័ន្ធ និងឧបសម្ព័ន្ធ, ឯកសារ E124/7, ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១, កថាខណ្ឌ ១២។ *សូមមើលផងដែរ* អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើង "សាក្សី, ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ក្រុមបន្ទាប់ដែលអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១", ឯកសារ E172, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១២, ទំព័រ ៤។

[3] សំណើរបស់សហព្រះរាជអាជ្ញាសុំបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម នៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/០១, ឯកសារ E163, ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១២, កថាខណ្ឌ ៤ ("សំណើ") (ដោយបញ្ជាក់លម្អិតអំពីទីកន្លែងទាំង ៣ ដែលបានស្នើដូចខាងក្រោម៖ ១) ការសម្លាប់ប្រជាជនជម្លៀសថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ នៅតាមទីកន្លែងនានាក្នុងស្រុកកំពង់ត្រឡាចលើ (ស្រុក ១២), ខេត្តកំពង់ឆ្នាំង (តំបន់ ៣១ នៃភូមិភាគបស្ចិម) (កថាខណ្ឌ ៦៩១,៦៩៣-៦៩៧ នៃដីកាដំណោះស្រាយ), ២) ការសម្លាប់អតីតទាហាន លន់ នល់ និងអ្នករដ្ឋការក្នុងឆ្នាំ ១៩៧៥ នៅទួលពោធិ៍ជ្រៃ ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ (តំបន់ ៧ នៃភូមិភាគពាយ័ព្យ) (កថាខណ្ឌ ៦៩៨-៧១១ នៃដីកាដំណោះស្រាយ) និង ៣) មន្ទីរសន្តិសុខ ស-២១ និងទីកន្លែងសម្លាប់មនុស្សដែលពាក់ព័ន្ធនៅឯជើងឯក ខេត្តកណ្តាល (កថាខណ្ឌ ៤១៥-៤៧៥ នៃដីកាដំណោះស្រាយ) *រួមទាំង* ការបោសសម្អាតកម្មាភិបាលមកពីភូមិភាគឧត្តរថ្មី, ភូមិភាគកណ្តាល (ឧត្តរចាស់) និងភូមិភាគបូព៌ា ដែលត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ (កថាខណ្ឌ ១៩២-២០៤ នៃដីកាដំណោះស្រាយ) ប៉ុន្តែពុំដាក់បញ្ចូលការដ្ឋាននៅព្រៃស ស្រុកដង្កោ ខេត្តកណ្តាលឡើយ)។

បានធ្វើពាក់ព័ន្ធនឹងសាក្សីថ្មីដែលត្រូវបានស្នើសុំឱ្យកោះហៅ ឬសាក្សីដែលពុំទាន់ត្រូវបានស្តាប់សក្ខីកម្ម តាមរយៈការពន្យារការពិនិត្យភស្តុតាងទាំងនេះទៅសវនាការនៅវគ្គក្រោយៗទៀត[4]។

៤. បើទោះបីជាយ៉ាងណាក្តី អង្គជំនុំជម្រះបារម្ភអំពីផលប៉ះពាល់ជាទូទៅដែលការពង្រីកវិសាលភាពដូចដែលបានស្នើសុំទាំងនេះ អាចមានចំពោះលទ្ធភាពនៃការបញ្ចប់ការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ បានឆាប់រហ័ស។ យោងតាមភស្តុតាងដែលត្រូវបានស្តាប់នៅចំពោះមុខអង្គជំនុំជម្រះមកទល់នឹងពេលបច្ចុប្បន្ន អង្គជំនុំជម្រះយល់ឃើញទៀតថា លក្ខណៈខ្លះនៃការពង្រីកវិសាលភាពនៃការជំនុំជម្រះ ដូចដែលសហព្រះរាជអាជ្ញាបានស្នើ ទំនងជាពុំបន្ថែមជាដុំកំភួនពីលើភស្តុតាងដែលស្ថិតនៅចំពោះមុខខ្លួនរួចហើយ ឬជាការបន្ថែមដែលពុំចាំបាច់។

៥. ដើម្បីត្រួសត្រាយការពិភាក្សាអំពីចំណុចបន្ថែមនៅឯកិច្ចប្រជុំរៀបចំសវនាការ ពាក់ព័ន្ធនឹងការស្នើសុំដើម្បីពង្រីកវិសាលភាពនៃសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងផ្តល់សេចក្តីវិភាគដូចខាងក្រោម អំពីចំណុចបន្ថែមដែលសហព្រះរាជអាជ្ញាបានស្នើសុំ និងគូសបញ្ជាក់អំពីចំណុចនានាដែលអង្គជំនុំជម្រះអាចត្រៀមរៀបចំដើម្បីពិចារណាអំពីការដាក់បញ្ចូលក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១។ ការវិភាគនេះផ្តោតលើចំណុចព្រួយបារម្ភមួយចំនួន ដែលអង្គជំនុំជម្រះនឹងស្នើសុំមតិយោបល់របស់សហព្រះរាជអាជ្ញានៅ ឯកិច្ចប្រជុំរៀបចំសវនាការ ព្រមទាំងមតិយោបល់របស់ភាគីដទៃទៀតផងដែរ។

## ក. ផលប៉ះពាល់នៃចំណុចបន្ថែមដូចដែលបានស្នើសុំទាំងនេះទៅលើសក្ខីកម្មរបស់សាក្សី

៦. ក្នុងសំណើ E163 សហព្រះរាជអាជ្ញាអះអាងថា ដើមបណ្តឹងរដ្ឋប្បវេណី, សាក្សី និងអ្នកជំនាញចំនួន ៣១ រូបដែលមានឈ្មោះរួចហើយនៅក្នុងបញ្ជីឈ្មោះបណ្តោះអាសន្នរបស់សាក្សី អ្នកជំនាញ និងដើម

[4] សំណើ, ជើងទំព័រ ៤៩ និង ៥០ (ដែលបង្ហាញអំពីសាក្សីដែលមានរហស្សនាម TCW-604, ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-142, សាក្សីដែលមានរហស្សនាម TCW-542, TCW-797, TCW-601, TCW-320, TCW-609 (ខែសីហា), TCW-475, TCW-694 (ដើមខែសីហា), TCW-586, TCW-724, TCW-323, TCW-796, TCW-490 (ខែ សីហា), TCW-707, TCW-794, TCW-234, TCW-583, TCW-321, TCW-91 (ត្រៀមបម្រុងនៅពាក់កណ្តាលខែ សីហា), ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-186, សាក្សីដែលមានរហស្សនាម TCW-428, TCW-645, TCW-487, TCW-297, TCW-110, TCW-326, TCW-281, អ្នកជំនាញដែលមានរហស្សនាម TCE-11, TCE-41, TCE-44)។

បណ្ដឹងរដ្ឋប្បវេណី (ឯកសារ E131/1.1) ក៏អាចមានលទ្ធភាពផ្ដល់ភស្ដុតាងស្ដីពីការពង្រីកវិសាលភាព ដែលត្រូវបានស្នើសុំទាំងនេះដែរ។ ដោយផ្អែកលើមូលដ្ឋាននេះ សហព្រះរាជអាជ្ញាអះអាងថា ការស្ដាប់សក្ខីកម្មបុគ្គលទាំងនេះស្ដីពីចំណុចបន្ថែមទាំងនេះនឹងពុំធ្វើឱ្យកិច្ចដំណើរការនីតិវិធីអូសបន្លាយយូរឡើយ[5]។

៧. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ក្នុងចំណោមបុគ្គលទាំង ៣១ រូបនេះ ១១ រូបពុំអាចទាក់ទងបាន ឬស្លាប់ ឬត្រូវបានអង្គជំនុំជម្រះសម្រេចថា ជាបុគ្គលដែលពុំចាំបាច់សម្រាប់ឱ្យអង្គជំនុំជម្រះស្ដាប់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១ ឡើយ ដោយសារពួកគាត់ពាក់ព័ន្ធតិចតួចបំផុតទៅនឹងកម្មវត្ថុនៃការជំនុំជម្រះ។ មនុស្សចំនួន ១០ នាក់ក្នុងចំណោមមនុស្សចំនួន ៣១ នាក់ ធ្លាប់ត្រូវបានអង្គជំនុំជម្រះស្ដាប់សក្ខីកម្មរួចហើយ។ ក្នុងចំណោមមនុស្សសេសសល់ចំនួន ១០ នាក់ ដែលពុំទាន់ត្រូវបានអង្គជំនុំជម្រះស្ដាប់សក្ខីកម្ម មនុស្សចំនួន ០៤ នាក់ជាមនុស្សពាក់ព័ន្ធនឹងចំណុចអង្គហេតុ ដែលត្រូវធ្វើសវនាការនាពេលបច្ចុប្បន្ន និងត្រូវបានកំណត់ពេលដើម្បីស្ដាប់សក្ខីកម្មនាពេលឆាប់ៗនេះ។ ចំណែកមនុស្សចំនួន ៦ នាក់ទៀតពុំទាន់ត្រូវបានអង្គជំនុំជម្រះកំណត់ពេលស្ដាប់សក្ខីកម្មនៅឡើយទេ។ បើទោះបីជាដូច្នេះក្ដី ក្នុងចំណោមមនុស្សចំនួន ០៦ នាក់នេះ មនុស្សចំនួន ០៣ នាក់ នាពេលបច្ចុប្បន្នត្រូវបានអង្គជំនុំជម្រះចាត់ទុកជាបេក្ខជនដែលត្រូវលុបឈ្មោះចេញពីបញ្ជី E131/1.1 (ដោយសារមានភាពពាក់ព័ន្ធតិចតួច) ដើម្បីរក្សាបាននូវភាពឆាប់រហ័សនៃការជំនុំជម្រះ។ ប្រការនេះនាំឱ្យគោលដៅនៃការស្ដាប់សក្ខីកម្មរបស់មនុស្សចំនួនទាំង ៣១ នាក់ស្ដីអំពីការចោទប្រកាន់លើអង្គហេតុដែលត្រូវបានពង្រីកបន្ថែម ពុំមានភាពងាយស្រួល ហើយផ្ទុយទៅនឹងការអះអាងរបស់សហព្រះរាជអាជ្ញា។ ការស្ដាប់សក្ខីកម្មនេះក៏អាចនឹងធ្វើឱ្យកិច្ចដំណើរការនីតិវិធីអូសបន្លាយយូរ (ជាសំខាន់ ប៉ះពាល់ដល់កិច្ចខិតខំរបស់អង្គជំនុំជម្រះសាលាដំបូងដើម្បីបង្កើនប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធី តាមរយៈការកាត់បន្ថយចំនួនបុគ្គលដែលត្រូវស្ដាប់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១)។ អង្គជំនុំជម្រះឯកភាពថា ការសួរសំណួរអំពីចំណុចបន្ថែមនៃការជំនុំជម្រះទៅសាក្សីដែលនឹងត្រូវផ្ដល់សក្ខីកម្ម ទំនងជាពុំធ្វើឱ្យដំណើរការនីតិវិធីអូសបន្លាយយូរឡើយ ហើយអង្គជំនុំជម្រះស្នើសុំសហព្រះរាជអាជ្ញាបញ្ជាក់ ក្នុងកិច្ចប្រជុំរៀបចំសវនាការថាតើសហព្រះរាជអាជ្ញានៅតែចង់បានចំណុចបន្ថែមដូចដែលបានស្នើសុំទាំងនេះដែរ ឬយ៉ាងណា

[5] ឯកសារ E163, កថាខណ្ឌ ៣០។

ដោយសារបុគ្គលដែលអាចផ្តល់សក្ខីកម្មដូចដែលសហព្រះរាជអាជ្ញាបានលើកឡើងមានចំនួនតិចតួច[6]។ អង្គជំនុំជម្រះនឹងពុំកោះហៅជាថ្មីនូវសាក្សីទាំងឡាយក្នុងចំណោមសាក្សីពាក់ព័ន្ធចំនួន ១០ នាក់ ដែលអង្គជំនុំជម្រះធ្លាប់បានស្តាប់សក្ខីកម្មរបស់ពួកគាត់រួចហើយ ប៉ុន្តែសំណើសុំកោះហៅសាក្សីជាថ្មីនេះអាចមាន បន្ទាប់ពីអង្គជំនុំជម្រះឯកភាពទៅលើផ្នែកបន្ថែមដែលបានស្នើសុំទាំងនេះ និងប៉ះពាល់មួយកម្រិតទៀត ទៅដល់លទ្ធភាពរបស់អង្គជំនុំជម្រះក្នុងការបញ្ចប់សំណុំរឿង ០០២/០១ បានឆាប់រហ័ស។

៨. សហព្រះរាជអាជ្ញាក៏បានស្នើសុំកោះហៅដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីបន្ថែមចំនួន ២៣ រូបពីក្នុងបញ្ជីឈ្មោះសាក្សីដំបូងរបស់សហព្រះរាជអាជ្ញា ដោយអនុលោមតាមវិធាន ៨០ ដើម្បីផ្តល់សក្ខីកម្មអំពីចំណុចបន្ថែម ដូចដែលបានស្នើសុំទាំងនេះ[7]។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ការបន្ថែមសក្ខីកម្មពីបុគ្គលចំនួន ២៣ រូបទៀតគឺជាការអូសបន្លាយកិច្ចដំណើរការនីតិវិធី យ៉ាងហោចណាស់ចំនួនពី ០៤ ទៅ ០៦ ខែ ដែរ។ នៅពេលពិនិត្យមើលឡើងវិញទៅលើចម្លើយរបស់បុគ្គលទាំងប៉ុន្មាន ដែលត្រូវបានស្នើសុំស្តាប់ចម្លើយ អង្គជំនុំជម្រះយល់ឃើញថា សក្ខីកម្មដែលពួកគាត់មួយចំនួននឹងផ្តល់ មានលក្ខណៈដូចគ្នា ឬពុំចាំបាច់។ ហេតុដូច្នេះ អង្គជំនុំជម្រះនឹងពិនិត្យមើលតែទៅលើសាក្សីបន្ថែមមួយចំនួនតូចដូចខាងក្រោមប៉ុណ្ណោះ៖

*i. ការសម្លាប់ប្រជាជនដែលត្រូវបានជម្លៀស ១៧ មេសា ឆ្នាំ ១៩៧៥ នៅតាមទីកន្លែងនានាក្នុងស្រុក កំពង់ត្រឡាចលើ (ស្រុក ១២)*

---

[6] សាក្សីទាំងនោះមានសាក្សីដែលមានរហស្សនាម TCW-428, TCW-310 និង TCW-326។ នៅដំណាក់កាលនេះ អង្គជំនុំជម្រះពុំមានបំណងស្តាប់សក្ខីកម្មរបស់សាក្សីដែលមានរហស្សនាម TCW-475, TCW-645 និងដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-186 ឡើយ។

[7] *សូមមើល*សំណើ, កថាខណ្ឌ ៣២ និងឧបសម្ព័ន្ធពាក់ព័ន្ធ E9/4.1 (ទាក់ទិននឹងទីកន្លែងសម្លាប់មនុស្សក្នុងស្រុក ១២, ដោយមានបង្ហាញអំពីសាក្សីដែលមានរហស្សនាម TCW-386, TCW-162, TCW-160, TCW-422, TCW-519, TCW-155, TCW-789, TCW-651, TCW-298, TCW-786, TCW-347 និង TCW-610 បន្ថែមពីលើសាក្សីដែលមានរហស្សនាម TCW-752, TCW-689, TCW-389, TCW-644, និង TCW-699 (ទួលពោធិជ្រៃ) និងសាក្សីដែលមានរហស្សនាម TCW-281, TCW-698, ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-21, សាក្សីដែលមានរហស្សនាម TCW-540, TCW-410 និង TCW-232 (ស-២១ និងជើងឯក))។

៩. ក្នុងសំណើរបស់ខ្លួន សហព្រះរាជអាជ្ញាស្នើសុំកោះហៅសាក្សីបន្ថែមចំនួន ១២ នាក់ដើម្បីបញ្ជាក់អំពីការចោទប្រកាន់ទាំងនេះ[8]។ អង្គជំនុំជម្រះចាត់ទុកសំណើនេះថាមានលក្ខណៈទូលំទូលាយពេកទាក់ទិននឹងការចោទប្រកាន់លើអង្គហេតុពាក់ព័ន្ធ និងទំនងជាមានភាពត្រួតជាន់គ្នាដែលពុំចាំបាច់។ បើទោះបីជាយ៉ាងណា អង្គជំនុំជម្រះអាចមានឆន្ទៈពិចារណាអំពីការកោះហៅសាក្សីបន្ថែមក្នុងចំនួនអតិបរមាពី ០៥ ទៅ ០៦ នាក់ ដោយយល់ឃើញថា សក្ខីកម្មរបស់សាក្សីដែលមានរហស្សនាម TCW-386, TCW-162, TCW-160, TCW-422, TCW-298 និង TCW-347 ទំនងជាមានតម្លៃជាភស្តុតាងច្រើនបំផុតទាក់ទិននឹងការចោទប្រកាន់ទាំងនេះ។ អង្គជំនុំជម្រះស្នើសុំឱ្យសហព្រះរាជអាជ្ញាពិចារណាបន្ថែមទៀតថាតើអង្គជំនុំជម្រះចាំបាច់ត្រូវស្តាប់ចម្លើយរបស់បុគ្គលទាំងអស់នេះ ដោយផ្ទាល់មាត់ដែរឬយ៉ាងណា ហើយថាតើជំនួសមកវិញ ចម្លើយរបស់បុគ្គលមួយចំនួនអាចមានភាពសមស្របដើម្បីឱ្យអង្គជំនុំជម្រះទទួលយក ដោយអនុលោមតាមសេចក្តីសម្រេច E96/7 ដែរ ឬយ៉ាងណា។

*ii. ការសម្លាប់អតីតទាហាន លន់ នល់ និងអ្នករដ្ឋការក្នុងឆ្នាំ ១៩៧៥ នៅទួលពោធិ៍ជ្រៃ ស្រុកកណ្តៀង ខេត្តពោធិ៍សាត់*

១០. អង្គជំនុំជម្រះយល់ឃើញថា ការកោះហៅសាក្សីចំនួន ០៥ នាក់ដើម្បីបញ្ជាក់អំពីការចោទប្រកាន់ទាំងនេះ ពុំមែនជាការចាំបាច់ឡើយ ហើយសាក្សីទាំង ០២ នាក់ខាងក្រោម ទំនងជាមានតម្លៃជាភស្តុតាងច្រើនបំផុតទាក់ទិននឹងការចោទប្រកាន់ទាំងនេះ។ សាក្សីទាំង ០២ នាក់នេះមានរហស្សនាម TCW-752 និង TCW-389។

*iii. មន្ទីរ ស-២១ និងជើងឯក*

១១. អង្គជំនុំជម្រះសាលាដំបូងពិចារណាល្អិតល្អន់ក្នុងការឯកភាពទៅលើចំណុចបន្ថែម ដែលបានស្នើសុំខាងលើនេះ ប៉ុន្តែយោងតាមសក្ខីកម្មរបស់ កាំង ហ្គេកអ៊ាវ នាពេលបច្ចុប្បន្ន (បន្ថែមពីលើភស្តុតាងទាំងអស់នៅតាមទីតាំងឧក្រិដ្ឋកម្ម ដែលមាននៅចំពោះមុខអង្គជំនុំជម្រះ ទាក់ទិននឹងប្រធានបទទាំងនេះ និងដែលអាចទទួលយកបានបន្ទាប់ពីមានសេចក្តីសម្រេច E96/7)។ អង្គជំនុំជម្រះយល់ឃើញថា ពុំមានភាពចាំ

---

[8] សាក្សីថ្មីៗដែលត្រូវបានស្នើសុំដែលមានរហស្សនាម P-023 – P-034 (ឯកសារ E9/4.1) (ដែលត្រូវជាសាក្សីដែលមានរហស្សនាម TCW-386, TCW-162, TCW-160, TCW-422, TCW-519, TCW-155, TCW-789, TCW-651, TCW-298, TCW-786, TCW-347 និង TCW-610។

បាច់ក្នុងការស្ដាប់សក្ខីកម្មរបស់សាក្សី ឬដើមបណ្ដឹងរដ្ឋប្បវេណីបន្ថែមទៀត ដើម្បីបញ្ជាក់អំពីឧក្រិដ្ឋកម្ម ដែលត្រូវបានប្រព្រឹត្តនៅមន្ទីរ ស-២១ និងនៅជើងឯកឡើយ។ សាក្សីបន្ថែមទាំងអស់ដែលសហព្រះរាជអាជ្ញាបានស្នើសុំកោះហៅលើបញ្ហានេះ គឺជាអ្នកបំពេញមុខងារនៅមន្ទីរស-២១ ក្រោមបង្គាប់របស់ កាំង ហ្គេកអ៊ាវ និងទំនងជាពុំមានលទ្ធភាពបញ្ជាក់អំពីការទទួលខុសត្រូវរបស់ជនជាប់ចោទក្នុងសំណុំរឿង ០០២/០១ បានឡើយ។

១២. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សំណើរបស់សហព្រះរាជអាជ្ញាត្រង់ផ្នែកនេះ ដាក់បញ្ចូលទាំងការបោសសម្អាតកម្មាភិបាលមកពីភូមិភាគឧត្តរថ្មី, ភូមិភាគកណ្ដាល (ឧត្តរចាស់) និងភូមិភាគបូព៌ា ដែលត្រូវបានបញ្ជូនទៅ ស-២១។ ទោះជាបែបនេះក៏ដោយ ក៏អង្គជំនុំជម្រះពុំទាន់ប្រាកដថាតើវិសាលភាពនៃសំណើនេះមានគោលបំណងបង្ហាញត្រួសៗ អំពីសកម្មភាពនៃការបោសសម្អាតទាំងនេះ ដែរ ឬយ៉ាងណា ឬគ្រាន់តែជាភស្តុតាងដែលបង្ហាញថា កម្មាភិបាលដែលមកពីភូមិភាគទាំងនេះ ត្រូវបានសម្លាប់នៅមន្ទីរ ស-២១។ ថ្វីបើចំណុចខាងក្រោយ ដែលអង្គជំនុំជម្រះសន្និដ្ឋានអាចត្រូវបានសង្ខេបនៅក្នុងផ្នែកខាងលើក៏ដោយ ក៏ចំណុចខាងដើមដែលអង្គជំនុំជម្រះសន្និដ្ឋាននឹងហាក់ដូចជាមានន័យស្មើនឹងការពង្រីកយ៉ាងទូលំទូលាយនៃវិសាលភាពនៃសំណុំរឿង ០០២/០១ និងពុំអាចត្រូវបានអង្គជំនុំជម្រះពិនិត្យពិចារណានៅដំណាក់កាលនេះបានឡើយ។

*iv. សាក្សីនានាដែលភាគីផ្សេងៗបានស្នើសុំកោះហៅដើម្បីផ្តល់សក្ខីកម្មលើចំណុចទាំងនេះ*

១៣. អង្គជំនុំជម្រះយល់ឃើញថា ប្រសិនបើសាក្សីបន្ថែមដែលសហព្រះរាជអាជ្ញាស្នើសុំកោះហៅ នឹងត្រូវបានស្ដាប់សក្ខីកម្មទាក់ទិននឹងចំណុចបន្ថែមដែលត្រូវបានស្នើសុំទាំងនេះ ដោយអនុលោមតាមក្របខណ្ឌគតិយុត្តនៅ អ.វ.ត.ក នោះ ភាគីផ្សេងៗក៏ត្រូវតែទទួលបានឱកាសក្នុងការបញ្ជាក់ថាតើពួកគេមានបំណងស្ដាប់សក្ខីកម្មរបស់សាក្សី ឬដើមបណ្ដឹងរដ្ឋប្បវេណីបន្ថែម បន្ទាប់ពីមានសក្ខីកម្មរបស់សាក្សីដែលសហព្រះរាជអាជ្ញាស្នើសុំកោះហៅដែរ ឬយ៉ាងណា។ នៅក្នុងកិច្ចប្រជុំរៀបចំសវនាការ អង្គជំនុំជម្រះមានបំណងចង់ឲ្យភាគីផ្សេងៗបញ្ជាក់ពីដំបូងអំពីអត្តសញ្ញាណនៃសាក្សី ឬដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួនតូច ដែលភាគីបានស្នើសុំកោះហៅ នៅក្នុងករណីដែលចំណុចបន្ថែមទាំងប៉ុន្មាន ដូចដែលបានបង្ហាញក្នុងផ្នែក ក(i)-(iii)(ខាងលើ) ទទួលបានការឯកភាព។

ខ. ឯកសារ

១៤. ប្រសិនបើចំណុចបន្ថែមខាងលើត្រូវបានអង្គជំនុំជម្រះឯកភាព ភាគីនឹងត្រូវការបន្ថែមទៀតនូវឱកាសដើម្បីកំណត់អត្តសញ្ញាណ និងស្នើសុំដាក់ឯកសារនានាពាក់ព័ន្ធនឹងផ្នែកបន្ថែមនៃឧក្រិដ្ឋកម្មដែលត្រូវបានដាក់បន្ថែមទៅលើវិសាលភាពនៃសំណុំរឿង ០០២/០១ បន្ទាប់ពីមានការឯកភាពនេះ។ បន្ទាប់មកទៀត ភាគីផ្សេងៗត្រូវតែទទួលបានឱកាសដើម្បីលើកការជំទាស់ណាមួយ ប្រសិនបើមានទៅនឹងឯកសារទាំងនេះ។ នៅក្នុងករណីដែលអង្គជំនុំជម្រះសម្រេចពង្រីកវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ សេចក្តីណែនាំបន្ថែមទាក់ទិននឹងឯកសារនឹងមាននៅពេលក្រោយតាមការសមស្រប ។

គ. កថាខណ្ឌនៃដីកាដំណោះស្រាយដែលពាក់ព័ន្ធ

១៥. សម្រាប់អង្គជំនុំជម្រះ ចំណុចធំបំផុតនៃភាពមន្ទិលគឺពាក់ព័ន្ធនឹងផ្នែកបន្ថែមទាំងស្រុងនៃដីកាដំណោះស្រាយដែលអាចចាំបាច់ត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង ០០២/០១ នៅក្នុងករណីដែលចំណុចបន្ថែមដូចដែលស្នើសុំទាំងនេះ ទទួលបានការឯកភាព (*សូមមើល* ឯកសារ E124/7.2)។ សហព្រះរាជអាជ្ញាបានបង្ហាញកថាខណ្ឌមួយចំនួននៃដីកាដំណោះស្រាយដែលចាំបាច់ ត្រូវដាក់បន្ថែមទៅលើវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ ប្រសិនបើអង្គជំនុំជម្រះឯកភាពទៅនឹងចំណុចបន្ថែមខាងលើ[9]។ កថាខណ្ឌដែលសហព្រះរាជអាជ្ញាបានបង្ហាញ ពាក់ព័ន្ធជាចម្បងទៅនឹងការចោទប្រកាន់អំពីទីតាំងឧក្រិដ្ឋកម្ម និងជាទូទៅពុំបញ្ជាក់អំពីគោលនយោបាយជាមូលដ្ឋាន ដែលញ៉ាំងឱ្យមានឧក្រិដ្ឋកម្មទាំងនេះ (ការសម្លាប់ខ្មាំង និងការដាក់ក្រុមមនុស្សជាក់លាក់ជាគោលដៅ) និងតួនាទីរបស់ជនជាប់ចោទទាក់ទិននឹងឧក្រិដ្ឋកម្មទាំងនេះឡើយ។ ការពិនិត្យមើលឡើងវិញរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើដីកាដំណោះស្រាយនៃសំណុំរឿង០០២ ទាំងមូលបង្ហាញថា កថាខណ្ឌមួយចំនួនធំនៃដីកាដំណោះស្រាយក៏ហាក់ដូចជាពាក់ព័ន្ធ ឬចាំបាច់សម្រាប់ដាក់បន្ថែម ដើម្បីធ្វើឱ្យចំណុចបន្ថែមដែលត្រូវបានស្នើសុំ

[9]កថាខណ្ឌបន្ថែមនៃដីកាដំណោះស្រាយដែលសហព្រះរាជអាជ្ញាបានស្នើសុំដាក់បញ្ចូល ដើម្បីគាំទ្រការពង្រីកវិសាលភាពដែលត្រូវបានស្នើសុំទាំងនេះ គឺកថាខណ្ឌ ៦៩១, ៦៩៣-៦៩៧ (ទាក់ទិននឹងការសម្លាប់ប្រជាជនជម្លៀសថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ នៅតាមទីកន្លែងក្នុងស្រុកកំពង់ត្រាចលើ (ស្រុក ១២)), កថាខណ្ឌ ៦៩៨-៧១១ (ទាក់ទិននឹងការសម្លាប់អតីតទាហាន លន់ នល់ និងអ្នករដ្ឋការក្នុងឆ្នាំ ១៩៧៥ នៅទួលពោធិ៍ជ្រៃ) និងកថាខណ្ឌ ៤១៥-៤៧៥ និងកថាខណ្ឌ ១៩២-២០៤ (ទាក់ទិននឹងមន្ទីរសន្តិសុខ ស-២១ និងទីកន្លែងសម្លាប់មនុស្សដែលពាក់ព័ន្ធនៅជើងឯក រួមទាំងការបោសសម្អាតកម្មាភិបាលពីភូមិភាគឧត្តរថ្មី, ភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) និងភូមិភាគបូព៌ា ដែលត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ ប៉ុន្តែពុំរាប់បញ្ចូលការដ្ឋាននៅឯព្រៃសឡើយ)។

ទាំងនេះមានភាពលម្អិតច្បាស់លាស់[10]។ អង្គជំនុំជម្រះស្នើសុំឱ្យសហព្រះរាជអាជ្ញាផ្តល់ការបញ្ជាក់បំភ្លឺជាបន្ទាន់ និងបញ្ជាក់ថាតើកថាខណ្ឌបន្ថែមណាខ្លះ ដែលអង្គជំនុំជម្រះបានបង្ហាញ ពុំត្រូវបានសហព្រះរាជអាជ្ញាពិចារណានៅក្នុងសំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំពង្រីកវិសាលភាពនៃការជំនុំជម្រះនេះ។

១៦. ការដាក់កថាខណ្ឌបន្ថែមនៃដីកាដំណោះស្រាយ បន្ថែមពីលើកថាខណ្ឌទាំងឡាយដែលសហព្រះរាជអាជ្ញាបានស្នើសុំ អាចមានផលប៉ះពាល់ជាសំខាន់មួយកម្រិតទៀតដល់សាក្សីដែលត្រូវស្តាប់សក្ខីកម្ម និងឯកសារពាក់ព័ន្ធនឹងការជំនុំជម្រះ (ខាងលើ) ព្រមទាំងសំណាងរដ្ឋប្បវេណី។

ឃ. <u>សេចក្តីសង្ខេប</u>

១៧. ក្នុងកិច្ចប្រជុំរៀបចំសវនាការ អង្គជំនុំជម្រះស្នើសុំឱ្យសហព្រះរាជអាជ្ញាបញ្ជាក់ថាតើខ្លួននឹងស្នើសុំចំណុចបន្ថែមនៅក្នុងក្របខ័ណ្ឌខាងលើដែរ ឬយ៉ាងណា។ ដូចដែលអង្គជំនុំជម្រះបានបញ្ជាក់ ភាគីផ្សេងៗក៏នឹងទទួលបានឱកាសសម្រាប់ការបញ្ចេញមតិយោបល់ផងដែរ។ អង្គជំនុំជម្រះប៉ាន់ប្រមាណថា ការកោះហៅសាក្សីថ្មីចំនួន ០៨ នាក់បន្ថែម ដែលជាចំនួនអប្បបរមាដែលត្រូវបានកាត់បន្ថយច្រើនពីសំណើរបស់សហព្រះរាជអាជ្ញា នឹងអូសបន្លាយការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ យ៉ាងហោចណាស់ចំនួន ០៣ ខែ នៅពេលពិចារណាអំពីតម្រូវការឱ្យមានចំណាត់ការលើបញ្ហាឯកសារ និងបញ្ហាសំខាន់ផ្សេងៗ ដូចដែលបានបញ្ជាក់ខាងលើ។

---

[10] កថាខណ្ឌបន្ថែមនៃដីកាដំណោះស្រាយដែលអាចពាក់ព័ន្ធ ឬសំខាន់ចំពោះការពង្រីកវិសាលភាពដែលត្រូវបានស្នើសុំទាំងនេះ ទាក់ទិននឹងតួនាទីរបស់ជនជាប់ចោទ នួន ជា គឺកថាខណ្ឌ ៩១៦-៩៧៧ (ទីកន្លែងសម្លាប់មនុស្ស និងមន្ទីរសន្តិសុខ), កថាខណ្ឌ ១៧៨-១៩១ (ការសម្លាប់ខ្មាំង -ទីកន្លែងសម្លាប់មនុស្ស និងមន្ទីរសន្តិសុខ), កថាខណ្ឌ ២០៧-២០៩ (ការដាក់ក្រុមមនុស្សជាក់លាក់ជាគោលដៅ អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ) កថាខណ្ឌ ៩៧៥-៩៧៧ (ដែលយកមនុស្សជាគោលដៅ អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ) និងកថាខណ្ឌ ៩៩៩-៩៧៤ (មន្ទីរស-២១), ទាក់ទិននឹងតួនាទីរបស់ជនជាប់ចោទ អៀង សារី, កថាខណ្ឌ ១០៥៨-១០៦៦ (ទីកន្លែងសម្លាប់មនុស្ស និងមន្ទីរសន្តិសុខ), កថាខណ្ឌ ១១០៥-១១១៣ (ការដាក់មនុស្សជាគោលដៅ អតីតអ្នករដ្ឋការនៃរបប សាធារណរដ្ឋខ្មែរ) និងកថាខណ្ឌ ១០៦៧-១០៨៩ (មន្ទីរ ស-២១) និងទាក់ទិននឹងតួនាទីរបស់ជនជាប់ចោទ ខៀវ សំផន, កថាខណ្ឌ ១១៧២-១១៨១ (ទីកន្លែងសម្លាប់មនុស្ស និងមន្ទីរសន្តិសុខ), ១១៩១-១១៩៣ (ដោយដាក់មនុស្សជាគោលដៅ អតីតអ្នករដ្ឋការនៃរបប សាធារណរដ្ឋខ្មែរ) និង (១១៨២-១១៩០)(មន្ទីរស-២១)។